# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ ០៩.០១២/០៧ គជប.អគ្គ.ពស** ភ្នំពេញ ថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ២០០៧

# គ្រូបង្គោល គ.ជ.ប ចំនួន ៨ រូប ទទួលបានការបណ្តុះបណ្តាលស្តីពី ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ប្រចាំឆ្នាំ ២០០៧

នៅរសៀលថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០០៧ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ( គ.ជ.ប ) បានបិទវគ្គបណ្តុះបណ្តាលស្តីពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត បន្ទាប់ពីបានធ្វើការបណ្តុះបណ្តាលដល់គ្រូបង្គោល និងមន្ត្រី គ.ជ.ប អស់រយៈពេលពីរថ្ងៃកន្លងមក ។

ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប បានមានប្រសាសន៍នៅក្នុងពិធីបិទវគ្គនោះថា នៅសប្តាហ៍ក្រោយ គ.ជ.ប នឹងធ្វើការបណ្តុះបណ្តាលរួមគ្នារវាងមន្ត្រីលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត (ប្រធាន អនុប្រធាន ជំនួយការបណ្តុះបណ្តាល និងព័ត៌មានសាធារណៈ នៃលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ) តំណាងគណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធនឹងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនេះដែរ ហើយភារកិច្ចរបស់ គ្រូបង្គោល គឺត្រូវធ្វើការបណ្តុះបណ្តាលដោយផ្ទាល់ដល់អ្នកទាំងនោះ ។

ឯកឧត្តមបានសង្កត់ធ្ងន់ថា គ្រូបង្គោលត្រូវយកចិត្តទុកដាក់ក្នុងការបង្រៀនដោយផ្តោតឱ្យចំលើការងារផ្នែកបច្ចេកទេស និងបទបញ្ញា និងនីតិវិធី ជាពិសេសនៅពេលបង្រៀន ត្រូវណែនាំដល់ មន្ត្រីលេខាធិការខេត្ត ក្រុងរៀបចំការបោះឆ្នោត ដើម្បីឱ្យពួកគាត់យកចិត្តទុកដាក់ក្នុងការអនុវត្តការងារ ឱ្យបានត្រឹមត្រូវតាមប្រតិទិនកំណត់ ត្រូវផ្តល់ព័ត៌មានមក គ.ជ.ប ឱ្យបានច្បាស់លាស់ក្នុងករណីអវិជ្ជមានណាមួយកើតឡើងនៅពេលអនុវត្តការងាររបស់ខ្លួន ។

តាមប្រតិទិននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៤ ឆ្នាំ ២០០៨ បានកំណត់ថា ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនឹងចាប់ផ្តើមពីថ្ងៃទី ១៥ ខែ កញ្ញា ដល់ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៧ ហើយការបិទផ្សាយបញ្ជីបោះឆ្នោតចុងក្រោយ ( បញ្ជីបោះឆ្នោតឆ្នាំ ២០០៦ ) នាថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០៧ នៅតាមសាលាឃុំ សង្កាត់ ។